ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៧៩៩
ចុះថ្ងៃទី ៣០_១២_២០០៩
សាលដីកា
លេខ : ១៨ "ក្រ.III.ស"
ចុះថ្ងៃទី ២៤_០១_២០១២

ដោយព្រះនាមព្រះមហាក្សត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ
**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៦_០១_២០១២ ដោយមានសមាសភាពដូចខាងក្រោម:

ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

ឯកឧត្តម [redacted]

ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៧៩៩ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted]ចាន់ធឿន ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរចាប់កាំង ទីលំនៅសព្វថ្ងៃ [redacted]ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted](រ) ម្ដាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន។

មានលោក[redacted]ចន្ថា ជាមេធាវីការពារ។

<u>ជាប់ចោទពីបទ:</u> **ប្លន់** ប្រព្រឹត្តនៅភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ហារឿន ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ ទីលំនៅសព្វថ្ងៃ ភូមិវត្តល្ងៀប សង្កាត់ចម្ការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

- តាមពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១០៦ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ធឿន** ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០១ "ង" ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទី ១ និងទី ២ នៃសេចក្ដីសម្រេច។





Scanned with CamScanner

ដំណើររឿងមានដូចតទៅ:

កាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ២ជិតភ្លឺ ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ចាន់ធឿន កាន់ដុំថ្មម្នាក់មួយដុំ ស្ទាក់បម្រុងវាយឈ្មោះ [redacted] សារឿន តែឈ្មោះ [redacted] សារឿន ដឹងខ្លួន ក៏ផ្ដួលរត់ចោលកង់ ក៏ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ចាន់ធឿន ជិះចេញទៅ។ លុះស្អែកឡើងក៏យកកង់នោះទៅលក់ឱ្យឈ្មោះ [redacted] គឹមហុន និងប្ដីឈ្មោះ [redacted] ថេន បានតម្លៃ ១៥.០០០រៀល ក្រោយមកឈ្មោះ [redacted] ម៉េង ខ្ចីកង់នោះពីឈ្មោះ [redacted] គឹមហុន ជិះ ទើបសមត្ថកិច្ចសាកសួរ ស្រាវជ្រាវរកឃើញជនជាប់ចោទទាំងពីរនាក់។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០១ "ង" ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:**

១- ផ្ដន្ទាទោសលើឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ២៣ឆ្នាំ និងឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស អាយុ ២១ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៥ឆ្នាំ ( ប្រាំឆ្នាំ) គិតពីថ្ងៃឃាត់ខ្លួនពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៩។

ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- បន្តការឃុំខ្លួនលើឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ចាន់ធឿន រហូតអនុវត្តទោសខាងលើចប់ជាស្ថាពរ។

៣- ឱ្យឈ្មោះ [redacted] គឹមហុន ភេទស្រី អាយុ ៥៥ឆ្នាំ រួចខ្លួនពីបទចោទប្រកាន់ ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិចម្ការសំរោង ២ សង្កាត់ចម្ការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៤- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ចាន់ធឿន, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] គឹមហុន។ បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១០៦ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០១ "ង" ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទី ១ និងទី ២ នៃសេចក្ដីសម្រេច។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន បានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង។

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឿន បានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង។ ឌ



Scanned with CamScanner

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

នៅក្នុងរឿងនេះសុំឱ្យក្រុមប្រឹក្សាពិចារណាតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

សូមក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួន តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់ ។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ១០៦ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- ជនជាប់ចោទបានឆ្លើយសារភាពថា កាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៩ ខ្លួនឃើញជនរងគ្រោះជិះកង់ម្នាក់ឯង ក៏ស្ទុះទៅបំណងវាយយកកង់ តែនៅពេលខ្លួនយាដៃឡើងវាយ ជនរងគ្រោះដឹងក៏ទម្លាក់កង់ចោល រត់ចេញបាត់ទៅ ខ្លួន និងឈ្មោះ [redacted] ចំរើន ជាគូកន ក៏យកកង់នោះទៅលក់បានប្រាក់ ១៥.០០០រៀល យកទៅចែកគ្នាស៊ីចាយ ។

៣- មានពិរុទ្ធលើជនជាប់ចោទ [redacted] ចាន់ធឿន ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ១០១ "ង" ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ១០៦ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០១ "ង" ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។



Scanned with CamScanner

៣- បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១២ ប្រកាសជាសាធារណៈនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១២ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃនេះទៅ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៚

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៤ ខែ ០៦ ឆ្នាំ ២០១៤

ក្រឡាបញ្ជី

Scanned with CamScanner